ឆ្នាំទី៦លេខ៤៧ចេញផ្សាយប្រចាំខែឧសភា ឆ្នាំ២០១៦

# ព្រឹត្តិបត្រការងារ
# Labour Bulletin

ជាស្ពានរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ⌖ Government gateway to ♦ Job ♦ Workforce ♦ Labour Market Information



រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល


- សកម្មភាពថ្មីៗពាក់ព័ន្ធវិស័យការងារ [ទំព័រ១]
- ព័ត៌មានទីផ្សារការងារនៅកម្ពុជា [ទំព័រ ៣]
- ព័ត៌មានជ្រើសរើសបុគ្គលិក [ទំព័រ ៧]

# ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## ព្រឹត្តិបត្រការងារ

---

# មាតិកា

## ព័ត៌មាន និងសកម្មភាព

❑ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាល ........ [ទំព័រ ១]

## ព័ត៌មានទីផ្សារការងារនៅកម្ពុជា

❑ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ពីខែមករា ឆ្នាំ២០១២ ដល់ខែមេសា ឆ្នាំ២០១៦ [ទំព័រ ៣]

## ព័ត៌មានជ្រើសរើសបុគ្គលិក

❑ ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែមេសា ឆ្នាំ២០១៦ ដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ [ទំព័រ ៧]

❀ចំណងជើងក្របមុខ៖ សកម្មភាពក្នុងសិក្ខាសាលា«ការត្រៀមលក្ខណៈសម្បត្តិចូលទីផ្សារការងារប្រកបដោយប្រសិទ្ធភាព»
❀ចំណងជើងក្របក្រោយ៖ អាសយដ្ឋានទីភ្នាក់ងារជាតិមុខរបរ និងការងារ


## ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន
ឯកឧត្តម ប៉ុក ប៉ាន់
ឯកឧត្តម ឡៅ ហ៊ីម
ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក ហៃ ហ៊ុនឡេង

**និពន្ធនាយករង**

លោក គួច សុមាន
លោក ទូច សុផាត

**ការីនិពន្ធ**

លោកស្រី លី វួចចេង
លោក សុជាតិ កញ្ញារិទ្ធ
កញ្ញា អ៊ូច ជាច័ន្ទមល្លិកា
លោក ស៊ីវ យាង
លោកស្រី ឌី ចង្កុលណី
មន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក គន់ សម្បត្តិ

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវស្មី

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូវ ឧស្សាហ៍រចនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី
លោក ផែន រដ្ឋា

**អ្នកពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធ**

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗ ពាក់ព័ន្ធនឹងវិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## សិក្ខាសាលានៅវិទ្យាស្ថានក្រុងអង្គរខេត្តកំពង់ធំ ស្តីពី «ការត្រៀមលក្ខណៈសម្បត្តិចូលទីផ្សារការងារដោយប្រសិទ្ធភាព»

**កំពង់ធំ៖** កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ មជ្ឈមណ្ឌលការងារខេត្តកំពង់ធំ (JCKT) នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ បានរៀបចំសិក្ខាសាលាមួយក្រោមប្រធានបទ: **«ការត្រៀមលក្ខណៈសម្បត្តិឈានចូលទីផ្សារការងារប្រកបដោយប្រសិទ្ធភាព»** ដែលត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលការងារខេត្តកំពង់ធំ និងមានការចូលរួមសហការក្នុងកម្មវិធីនោះជាមួយ វិទ្យាស្ថានជាតិក្រុងអង្គរ និងធនាគារLOLC ដើម្បីបណ្តុះបណ្តាលទៅដល់សាធារណជនទូទៅ និងនិស្សិត នៃវិទ្យាស្ថានជាតិក្រុងអង្គរ បានចូលរួមប្រមាណជាង ១០៣នាក់ ក្នុងនោះស្រីមានចំនួន ៧០នាក់ នឹងត្រូវបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សានាពេលឆាប់ៗខាងមុខនេះឱ្យទទួលបាននូវ៖

- បទពិសោធន៍ល្អៗ សម្រាប់និស្សិតឱ្យចេះពីការរៀបចំខ្លួនមុន និងក្រោយបញ្ចប់ការសិក្សា
- ស្វែងយល់អំពីការរៀបចំផែនការអាជីព និងរបៀបក្នុងការជ្រើសរើសជំនាញ
- គោលការណ៍គ្រឹះសំខាន់ៗ ដើម្បីរៀបចំផែនការឱ្យទទួលបានជោគជ័យ
- ការចែករំលែកបទពិសោធន៍ល្អៗ ពីការអភិវឌ្ឍខ្លួនឱ្យប្រសើរឡើង
- យល់ដឹងពីគោលការណ៍ និងបែបបទនៃការងាររបស់ក្រុមហ៊ុន
- គន្លឹះសំខាន់ៗសម្រាប់ធ្វើការរៀបចំគោលដៅអនាគត

សិក្ខាសាលានេះបានផ្តល់នូវធនធានគំនិតជាមូលដ្ឋានដ៏ចាំបាច់ដល់និស្សិត ក្នុងការត្រៀមលក្ខណៈសម្បត្តិក្នុងការចាប់យកជំនាញរបស់ខ្លួនឱ្យត្រូវនឹងទីផ្សារការងារប្រកបដោយជំនាញ គុណភាព គុណតម្លៃ និងការអភិវឌ្ឍខ្លួន ដើម្បីធ្វើការស្វែងយល់ពីខ្លួនឯង ក្នុងការរៀបចំផែនការអាជីពឱ្យបានល្អសមរម្យទៅតាមតម្រូវការជំនាញ ឆ្លើយតបឱ្យទាន់ពេលទៅនឹងកាលានុវត្តភាពសង្គម គឺពិតជារឿងមួយដ៏សំខាន់ណាស់សម្រាប់និស្សិតនាពេលអនាគត។








តទៅទំព័របន្ទាប់



# សិក្ខាសាលាស្តីពី«ការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សា»

## វិទ្យាល័យហ៊ុនសែនពាមជីកង ខេត្តកំពង់ចាម

**កំពង់ចាម៖** កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ មជ្ឈមណ្ឌលការងារខេត្តកំពង់ចាម (JCKC) នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលដល់សាធារណជនទូទៅ សិស្ស និស្សិត និងអ្នកស្វែងរកការងារ នៅវិទ្យាល័យហ៊ុនសែនពាមជីកង ខេត្តកំពង់ចាម ដែលបានចូលរួមសហការដោយ គណៈគ្រប់គ្រងវិទ្យាល័យ ហើយមានសិស្សានុសិស្សចូលរួមយ៉ាងច្រើនកុះករប្រមាណជាង ១០៩នាក់ ក្នុងនោះស្រីមានចំនួន ៥៣នាក់ ដែលពួកគេនឹងត្រូវប្រលងបញ្ចប់មធ្យមសិក្សាទុតិយភូមិនាពេលឆាប់ៗខាងមុខនេះ ហើយនឹងត្រូវធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសជំនាញសិក្សា ដើម្បីបន្តថ្នាក់ឧត្តមសិក្សាឱ្យសមស្របទៅតាមតម្រូវការទីផ្សារការងារ ឬជ្រើសរើសមុខរបរការងារ និងវិជ្ជាជីវៈណាមួយឱ្យសមស្របទៅតាមជំនាញឯកទេសរបស់ខ្លួន ដូចជាយើងទាំងអស់គ្នាបានដឹងរួចមកហើយថា ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវការធនធានមនុស្ស ដែលមានគុណភាព ដើម្បីឆ្លើយតបឱ្យទាន់ពេលនឹងកាលានុវត្តភាពក្នុងសង្គមបច្ចុប្បន្ននេះ គឺពិតជារឿងមួយដ៏សំខាន់ណាស់។

សិក្ខាសាលានេះបានផ្តល់នូវធនធានគំនិតជាមូលដ្ឋានដ៏ចាំបាច់ដល់សិស្ស-និស្សិត ក្នុងការត្រៀមលក្ខណៈសម្បត្តិឈានជើងចូលទៅទីផ្សារ ការងារប្រកបដោយជំនាញ គុណភាព គុណតម្លៃ និងការអភិវឌ្ឍខ្លួន ហើយធ្វើការស្វែងយល់ពីចំណេះដឹងជំនាញ និងការចាប់យកអាជីពរបស់ខ្លួនឯង ក្នុងការរៀបចំផែនការអាជីពនាពេលបញ្ចប់ការសិក្សា ផ្អែកលើការសម្រេចចិត្តដោយពឹងផ្អែកលើកត្តា៤សំខាន់ៗដូចជា ជំនាញ ចំណូលចិត្ត គុណតម្លៃ និងបុគ្គលិកលក្ខណៈ ដើម្បីងាយស្រួលចាប់យកនូវឱកាសអាជីពការងារល្អៗបានឆាប់ ហើយសមរម្យទៅតាមជំនាញសិក្សា។







ព័ត៌មានទីផ្សារការងារ

# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរនិងការងារ ពីខែមករា ឆ្នាំ២០១២ ដល់ ខែមេសា ឆ្នាំ២០១៦

អត្ថបទនេះមានបំណងបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មនាពេលបច្ចុប្បន្ន ក្នុងទីផ្សារការងារកម្ពុជា តាមរយៈទិន្នន័យស្ថិតិអ្នកចុះឈ្មោះស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ចាប់ពីខែមករា ឆ្នាំ២០១២ ដល់ខែមេសា ឆ្នាំ២០១៦។ ទិន្នន័យទាំងនោះ រួមមានអ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ២៤.២៦៣នាក់ (មិនរួមបញ្ចូលអ្នកស្វែងរកការងារធ្វើ ដែលបានប្រមូលនៅតាមមូលដ្ឋាន) និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២១៤.៣៤៦នាក់ ។ ជាថ្មីម្តងទៀត ទ.ជ.ម.ក សូមបញ្ជាក់ថាទិន្នន័យដែលបាន និងកំពុងលើកយកមកបង្ហាញជូនក្នុងផ្នែកនេះ គឺមិនគ្របដណ្តប់លើទិន្នន័យសម្រាប់ប្រទេសកម្ពុជាទាំងមូលទេ ដូច្នេះរាល់ការប្រើប្រាស់ និងការបកស្រាយទិន្នន័យទាំងនេះ ត្រូវពិចារណានូវបញ្ហានេះ។

### ១. ចំនួនអ្នកស្វែងរកការងារធ្វើនិងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)

ដើម្បីធ្វើការបង្ហាញអំពីស្ថានភាពទីផ្សារការងារមួយ យើងចាំបាច់ត្រូវតែធ្វើការពិចារណាទៅលើតម្រូវការ និងការផ្គត់ផ្គង់នៃកម្លាំងពលកម្មនៅក្នុងទីផ្សារនេះ។ ប៉ុន្តែការវិភាគ ពិចារណាពីកម្លាំងពលកម្មអាចធ្វើឡើងក្នុងទម្រង់ និងរូបភាពច្រើនសណ្ឋាន។ ក្នុងចំនុចនេះ ទ.ជ.ម.ក សូមលើកយកការប្រៀបធៀបរវាងចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ISCO) មកធ្វើការបង្ហាញជូន។ បើពិនិត្យមើលទៅលើក្រុមចំណាត់ថ្នាក់មុខរបរធំបំផុត (Major Occupation) ដែលបានបង្ហាញជូនក្នុងរូបទី១ (ទំព័របន្ទាប់) ឃើញថាក្រុមដែលមានការផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេ គឺក្រុមអ្នកជំនាញឯកទេសវិជ្ជាជីវៈដែលមានអត្រារហូតដល់ ៣១,៥% នៃចំនួនអ្នកស្វែងរកការងារធ្វើសរុប ដែលប្រមូលដោយ ទ.ជ.ម.ក ចំណែកតម្រូវការកម្លាំងពលកម្មសម្រាប់ក្រុមជំនាញដូចគ្នានេះ គឺមានត្រឹមតែ ៨,៤% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើផ្នែកតម្រូវការកម្លាំងពលកម្មវិញ ឃើញថាក្រុមដែលមានតម្រូវការខ្ពស់ជាងគេ គឺកម្មករជំនាញផ្នែកសិប្បកម្ម និងកម្មករជំនាញពាក់ព័ន្ធ ដែលមានអត្រារហូតដល់ ៣៩,៨% នៃតម្រូវការកម្លាំងពលកម្មសរុបដែលបានប្រមូលដោយ ទ.ជ.ម.ក រីឯការផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់ក្រុមចំណាត់ថ្នាក់មុខរបរដូចគ្នានេះមានត្រឹមតែ ៧,៤% ប៉ុណ្ណោះ។


តទៅទំព័របន្ទាប់

រូបទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.២៦៣នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២១៤.៣៤៦នាក់

## ២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)

បើពិនិត្យមើលទៅលើចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកទៅតាមវិស័យធំៗទាំងបីនៃសកម្មភាពសេដ្ឋកិច្ច យើងចាប់អារម្មណ៍ឃើញថាការផ្គត់ផ្គង់កម្លាំងពលកម្ម បានប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម តាមពីក្រោយរៀងគ្នាដោយវិស័យឧស្សាហកម្ម និងកសិកម្ម ខណៈតម្រូវការកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មមានកម្រិតខ្ពស់ជាងគេ (រូបទី២)។ ក្នុងនោះ យើងសង្កេតឃើញថានៅក្នុងវិស័យសេវាកម្ម ចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មានអត្រា ៥៤,២%ខ្ពស់ជាងព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)ដែលមានអត្រា ៤១,១%ប៉ុណ្ណោះ។ ចំណែកវិស័យឧស្សាហកម្មវិញ ឃើញថាព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) មានអត្រាប្រមាណ ៥៦,៣% ចំណែកឯចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) ក្នុងវិស័យនេះវិញមានអត្រាត្រឹមតែ ១៥,២%។

រូបទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមវិស័យសេដ្ឋកិច្ច (ខែមករា ឆ្នាំ២០១២ ខែមេសា ឆ្នាំ២០១៦)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.២៦៣នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២១៤.៣៤៦នាក់

តារាងទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច
(ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)

| ចំណាត់ថ្នាក់នៃសហគ្រាស | | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| A | កសិកម្ម និងរុក្ខាប្រមាញ់ | 421 | 1.7 | 4,168 | 1.9 |
| B | រ៉ែ និងថ្ម | 13 | 0.1 | 196 | 0.1 |
| C | កម្មន្តសាល | 2,882 | 11.9 | 111,741 | 52.1 |
| D | អគ្គិសនី ឧស្ម័ន ចំហាយ និងផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | 717 | 3.0 | 8,372 | 3.9 |
| E | ផ្គត់ផ្គង់ទឹក លូទឹក គ្រប់គ្រងសំរាម និងសកម្មភាពផ្សេងៗ | 77 | 0.3 | 348 | 0.2 |
| F | សំណង់ | 284 | 1.2 | 2,970 | 1.4 |
| G | លក់ដុំ និងរាយ | 905 | 3.7 | 6,881 | 3.2 |
| H | ដឹកជញ្ជូន ស្តុក និងឃ្លាំង | 134 | 0.6 | 999 | 0.5 |
| I | សណ្ឋាគារ ការស្នាក់អាស្រ័យ អាហារ ភេសជ្ជៈ និងសេវាផ្សេងៗ | 1,411 | 5.8 | 15,405 | 7.2 |
| J | ព័ត៌មាន និងទូរគមនាគមន៍ | 1,127 | 4.6 | 7,649 | 3.6 |
| K | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 3,326 | 13.7 | 22,595 | 10.5 |
| L | អចលនទ្រព្យ | 42 | 0.2 | 558 | 0.3 |
| M | វិជ្ជាជីវៈ បច្ចេកទេស និងវិទ្យាសាស្ត្រ | 1,906 | 7.9 | 2,808 | 1.3 |
| N | រដ្ឋបាល និងសេវាគាំទ្រ | 721 | 3.0 | 3,276 | 1.5 |
| O | រដ្ឋបាលសាធារណៈ និងការពារ | 225 | 0.9 | 2,240 | 1.0 |
| P | អប់រំ | 1,454 | 6.0 | 6,917 | 3.2 |
| Q | សុខភាព និងសេវាសង្គម | 530 | 2.2 | 2,109 | 1.0 |
| R | សិល្បៈ ការកំសាន្ត និងការច្នៃប្រឌិត | 28 | 0.1 | 3,217 | 1.5 |
| S | សេវាផ្សេងៗ | 801 | 3.3 | 7,767 | 3.6 |
| T | សកម្មភាពជានិយោជកនៅក្នុងផ្ទះដោយប្រកបអាជីវកម្ម ឬសេវាផ្សេងៗ | 32 | 0.1 | 355 | 0.2 |
| U | សកម្មភាពរបស់ស្ថានទូត កុងស៊ុល និងអង្គការអន្តរជាតិ | 217 | 0.9 | 2,282 | 1.1 |
| V | ផ្សេងៗ | 7,010 | 28.9 | 1,493 | 0.7 |
| **សរុប** | | 24,263 | 100.0 | 214,346 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.២៦៣នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២១៤.៣៤៦នាក់

## ៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំបណ្ដុះបណ្ដាល (ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)

ដោយផ្អែកលើទិន្នន័យនៃចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលប្រមូលដោយ ទ.ជ.ម.ក ដោយបែងចែកតាមកម្រិតអប់រំ (រូបទី៣) ឃើញថាអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មួយភាគធំ ប្រមាណជា ៤៨,៤% កាន់សញ្ញាបត្របរិញ្ញាបត្រ ចំណែកឯព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) កម្រិតបរិញ្ញាបត្រវិញមានត្រឹមតែ ១៣,៥% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)វិញឃើញថា តម្រូវការកម្លាំងពលកម្មមួយភាគធំ គឺមិនទាមទារឱ្យមានបញ្ចប់ថ្នាក់សិក្សាណាមួយឡើយ ដែលមានអត្រារហូតដល់ ៦៣,១% ដែលជាអត្រាមួយខ្ពស់ខ្លាំង បើប្រៀបធៀបជាមួយនឹងចំនួនអ្នកស្វែងរកការងារធ្វើ ដែលមានកម្រិតអប់រំដូចគ្នានេះមានត្រឹមតែ ១៤,០%ប៉ុណ្ណោះ។

រូបទី៣ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតអប់រំបណ្ដុះបណ្ដាល (ខែមករា ឆ្នាំ២០១២ - ខែមេសា ឆ្នាំ២០១៦)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.២៦៣នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២១៤.៣៤៦នាក់

*អត្ថបទស្ដីពី ព័ត៌មានទីផ្សារការងារនៅកម្ពុជា រៀបចំ និងបកស្រាយពន្យល់ដោយ **ការិយាល័យស្រាវជ្រាវ វិភាគ និងព្យាករណ៍ព័ត៌មានទីផ្សារការងារ** យោងតាមមូលដ្ឋានទិន្នន័យដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ។*



# ព័ត៌មានជ្រើសរើសបុគ្គលិក

## VACANCY ANNOUNCEMENT

ព័ត៌មានជ្រើសរើសបុគ្គលិក

## ដើម្បីទទួលបានសេវាការងារដោយ «ឥតគិតថ្លៃ» សូមទំនាក់ទំនង ឬធ្វើដំណើរមកកាន់៖

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ □**មជ្ឈមណ្ឌលការងារ**□ ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះ ពីគេហទំព័ររបស់យើង www.nea.gov.kh/jobshop

### ម.ភ រាជធានីភ្នំពេញ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
023 633 6002 ឬ 077 232 378 ឬ016 786 655
jc_pp@nea.gov.kh

### ម.ភ ខេត្តបាត់ដំបង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
បាត់ដំបង ផ្លូវលេខ២០១ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
053 733 111 ឬ 016 926 655
jc_battambang@nea.gov.kh

### ម.ភ ខេត្តកំពត

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
កំពត ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត
033 210 277 ឬ 016 506 655
jc_kampot@nea.gov.kh

### ម.ភ ខេត្តកំពង់ចាម

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ចាម ផ្លូវលេខ៧ចាស់ ភូមិទី៧
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
042 210 277 ឬ 016 656 655
jc_kampongcham@nea.gov.kh

### ម.ភ ខេត្តសៀមរាប

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
សៀមរាប សង្កាត់ស្លក្រាម
ក្រុងសៀមរាប
063 210 277ឬ 016 536 655
jc_siemreap@nea.gov.kh

### ម.ភ ខេត្តស្វាយរៀង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
ស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង
044 715 277 ឬ 016 646 655
jc_svayrieng@nea.gov.kh

### ម.ភ ខេត្តកំពង់ធំ

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ធំ ភូមិអាចារ្យលាក់ សង្កាត់
អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
062 210 277 / 016 836 655
jc_kampongthom@nea.gov.kh

### ម.ភ ខេត្តព្រៃវែង

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តព្រៃវែង ភូមិ១សង្កាត់កំពង់លាវ
ក្រុងព្រៃវែង ខេត្តព្រៃវែង
081 786 655 / 043 210 277
jc_preyveng@nea.gov.kh

### ម.ភ ខេត្តតាកែវ

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
តាកែវ ក្នុងភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ
ខេត្តតាកែវ
032 210 277 ឬ 016 676 655
jc_takeo@nea.gov.kh



ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ / 023 884 692 ឬ 088 678 5678 / info@nea.gov.kh

**ឥឡូវនេះ អតិថិជនរបស់ □□□□□□ អាចធ្វើការហៅចូលដោយ □ឥតគិតថ្លៃ□ មកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!**


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## Desjoyaux Cambodia co.,ltd

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. Receptionist

**លក្ខខណ្ឌជ្រើសរើស:**

- ចេះភាសាអង់គ្លេសអាចប្រើការបានក្នុងមុខងា
- ចេះប្រើប្រាស់កុំព្យូទ័រ
- មានភាពរួសរាយរាក់ទាក់
- មានភាពស្មោះត្រង់ និងព្យាយាមក្នុងការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៤៤២ ផ្លូវ ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

☎ ០៩៦ ៥៨៨ ១២ ៨៨/ ០១៦ ៤៤ ៧៧ ៥៧

✉ Sreythan.chheang@kvvdesjoyaux.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Khmer Brewery Limited

**ថ្ងៃផុតកំណត់:** ២៣ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ជំនួយការចុងភៅ

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ខាងកូនកាំបិត
- កម្រិតវប្បធម៌ថ្នាក់ទី១២ ឡើងទៅ និងមានសញ្ញាបត្រជំនាញចុងភៅកាន់តែប្រសើរ
- ស្មោះត្រង់រួសរាយរាក់ទាក់ និងព្យាយាមធ្វើការ
- អាយុចាប់ពី ១៨-៤០ឆ្នាំ
- មានភាពអំណត់ក្នុងការងារ ស្មោះត្រង់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ១៩H ផ្លូវ២៧១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០៨៦ ៥៥៥ ៧០៣

✉ career@khmerbrewery.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## South East Asia Telecom (Cambodia) Co.,Ltd

**ថ្ងៃផុតកំណត់:** ០៨ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ភ្នាក់ងារសេវាកម្មអតិថិជនផ្នែកភាសាកូរ៉េ (ចំនួន ០១នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ពូកែខាងស្តាប់ និយាយ អាន ភាសាកូរ៉េ
- មានទំនួលខុសត្រូវខ្ពស់ក្នុងការងារ
- មានសមត្ថភាពខ្ពស់ក្នុងការស្តាប់
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាអតិថិជន
- មានអំណត់ក្នុងការងារ
- មានភាពរួសរាយរាក់ទាក់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១៤៩ ផ្លូវ៤៣២ ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

☎ ០១៨ ៩៧០០២៦២

✉ tangfengqiong@seatelgroup.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## Konkhmer Communication Co., Ltd.

**ថ្ងៃផុតកំណត់:** ២៥ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកនិយាយភាសាចិន (ចំនួន ០១នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានចំណេះដឹងផ្នែកភាសាចិន
- អាចស្តាប់ អាន និយាយភាសាចិនបានយ៉ាងស្ទាត់ជំនាញ
- មានបទពិសោធន៍ទាក់ទងនឹងមុខតំណែង
- មានភាពស្មោះត្រង់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្លូវព្រះមុនីវង្ស (៨០៧) សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

☎ ០២៣ ៩៩៣ ២២១

Cambodia@realmax.co.jp

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Sinamyang Cambodia Co.,Ltd

**ថ្ងៃផុតកំណត់:** ០៨ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ប្រធានបច្ចេកទេសផ្សព្វផ្សាយ

**លក្ខខណ្ឌជ្រើសរើស:**

- បញ្ចប់បរិញ្ញាបត្រផ្នែកកសិកម្ម
- ត្រូវមានបទពិសោធន៍ ០២ឆ្នាំទាក់ទងមុខតំណែង
- មានការប្រាស្រ័យទំនាក់ទំនងល្អ
- មានភាពអត់ធ្មត់ក្នុងការងារ
- ត្រូវមានចំណេះដឹងផ្នែកភាសាអង់គ្លេស
- មានទំនាក់ទំនងល្អជាមួយអ្នកដទៃ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ 72D ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

☎ ០៧៨ ៥៩១ ៣៣៣

1812264186@qq.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Café Sushi

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែករត់តុ (ចំនួន ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- អាចនិយាយ និងសរសេរភាសាអង់គ្លេសបានខ្លះៗ

**សូមទំនាក់ទំនងតាមរយៈ:**

#6HEo, ផ្លូវសម្តេចសុធារស់ រាជធានីភ្នំពេញ

☎ ០៩២ ៦៩៥១០៧

saicam@online.com.kh

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## IDD Cambodia

**ថ្ងៃផុតកំណត់:** ២៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកដឹកជញ្ជូន (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ចប់មធ្យមសិក្សាថ្នាក់ទី១២
- ធ្លាប់ធ្វើការផ្នែកដឹកជញ្ជូនពីមុនមក


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

- ចេះប្រើប្រាស់ម៉ូតូកង់បី អំប្រីយ៉ា
- អាចនិយាយ និងអាន ភាសាអង់គ្លេសបានខ្លះៗ
- មានការទទួលខុសត្រូវ និងគោរពពេលវេលា

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ២៦៣ ផ្លូវលេខ១១៨ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០១៧ ២៩២ ២៦៦

job@iddcambodia.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## អង្គការស្ពានជីវិត (SCO)

**ថ្ងៃផុតកំណត់:** ០៩ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. មន្ត្រីឥណទាន (ចំនួន ១០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានកំរិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររង រឺឆ្នាំទី១ឡើងទៅ
- មានជំនាញក្នុងការផ្តល់សេវាកម្មល្អ ទំនាក់ទំនងល្អ និងការដោះស្រាយបញ្ហាកាន់តែប្រសើរ
- មានសីលធម៌ល្អ អាកប្បកិរិយាល្អ ស្មោះត្រង់ ការប្តេជ្ញាចិត្តខ្ពស់ ការគោរពវិន័យ និងមានគំនិតជាសហគ្រិន
- ផ្តល់អាទិភាពចំពោះបេក្ខជនដែលរស់នៅក្នុងតំបន់ប្រតិបត្តិការជ្រើសរើសបុគ្គលិករបស់អង្គការស្ពានជីវិត

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ១៧៧ ផ្លូវ៣១BT ភូមិសន្សំកុសល់២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

☎ ០១០ ៩៩៩៧ ៨៧១

info@scocambodia.org

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## SAMLANH FINANCE CRREDIT OPERATOR

**ថ្ងៃផុតកំណត់:** ១៣ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ជំនួយការបម្រើអតិថិជន (ចំនួន ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ប្រលងជាប់ ឬ ធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ជានីតិជន មានចរិតស្លូតបូត និងក្រមសីលធម៌ល្អ
- មានឆន្ទៈខ្ពស់ក្នុងតួនាទី និងភារៈកិច្ច
- មានភាពស្មោះត្រង់

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ២០៩ ផ្លូវលេខ១១ ភូមិសំបួរ (បុរីពិភពថ្មី ចំការដូង) សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

☎ ០៨៦ ៣០១ ១១១/០៩២ ២៧២ ៦២៦

pysethlun3008@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## PHARMA PRODUCT MANUFACTURING CO.,

**ថ្ងៃផុតកំណត់:** ១២ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. QC Analyst

**លក្ខខណ្ឌជ្រើសរើស:**

- កម្រិតសិក្សាចាប់ពីបរិញ្ញាបត្ររងទាក់ទងផ្នែកគីមីចំណីអាហារ
- ត្រូវមានបទពិសោធន៍ទាក់ទងមុខតំណែងយ៉ាងតិច១ឆ្នាំ
- ចេះវិភាគថ្នាំគ្រប់ទម្រង់ ប្រើប្រាស់ម៉ាស៊ីន Dissolution Test, Spectro
- អាចប្រើប្រាស់កម្មវិធីកុំព្យូទ័របានស្ទាត់ជំនាញ
- មានភាពអត់ធ្មត់ក្នុងការងារ

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ១១៣៨Bis ផ្លូវ១១០ សង្កាត់ចោមចៅ រាជធានីភ្នំពេញ

☎ ០២៣ ៦៩ ២៧ ០៦៦

✉ Recruitment@ppmpharma.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## BSC Computer

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់(Indoor)

២. ផ្នែកជាងជួសជុល

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានចំនេះដឹងផ្នែកពត៌មានវិទ្យា
- ត្រូវចេះបញ្ចូលទឹកថ្នាំ Printer
- ធ្លាប់មានបទពិសោធន៍ជួសជុល ចេះមេកានិច គ្រឿង Electronic
- ចេះជួសជុល Printer ម៉ាញ៉េ ទូរទស្សន៍
- អាចទំនាក់ទំនងជាភាសាខ្មែរ និងអង់គ្លេស
- មានភាពរួសរាយរាក់ទាក់
- មានភាពស្មោះត្រង់ អត់ធ្មត់ ស្រឡាញ់ចំពោះការងារ
- មានបទពិសោធន៍ទាលើការលក់ដូរទំនិញទូរទៅ

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ៣៧០ ផ្លូវ១២៨ កម្ពុជាក្រោម សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ

☎ ០៩៣ ២២ ៩៨ ८៩

✉ amveasna82@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ROSE EMERALD HOTEL

**ថ្ងៃផុតកំណត់:** ២៩ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នករៀបចំបន្ទប់ (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ទាំងពីរភេទ
- ចេះអត់ធ្មត់និងការងារ
- រួសរាយរាក់ទាក់
- ស្មោះត្រង់
- មានបទពិសោធន៍កាន់តែល្អ

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ៣៦ ផ្លូវ២៣២ កែងផ្លូវ១១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា

☎ ០៩៩ ៩២ ៦៦ ៦៦

✉ Hourt_siv@yahoo.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## The CamElite School

**ថ្ងៃផុតកំណត់:** ៣០ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ភ្នាក់ងារផ្តល់ព័ត៌មាន (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- វិញ្ញាបនបត្ររង-បរិញ្ញាបត្រជំនាញ គណនេយ្យ ឬធនាគារ ឬ ជំនាញពាក់ព័ន្ធ
- ចេះភាសាអង់គ្លេសប្រើប្រាស់
- ចេះកុំព្យូទ័រ យ៉ាងហោចណាស់ត្រឹម កុំព្យូទ័រសម្រាប់ការិយាល័យ



តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

- មានបទពិសោធន៍ការងារលើជំនាញដែលដាក់ពាក្យយ៉ាងហោចណាស់មួយឆ្នាំ
- អាចបម្រើការជូនសាលារៀន ខេមអេលីត បានយ៉ាងហោចណាស់២ឆ្នាំ
- មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន
- គោរពពេលវេលា និងមានសុខភាពល្អ
- មានរូបសម្បត្តិសមរម្យ
- មានសុជីវធម៌ល្អ ក្លាហាន និងចេះទទួលខុសត្រូវ

**សូមទំនាក់ទំនងតាមរយៈ**

អគារលេខ១៦២ ផ្លូវ១៤៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

០៨៩ ២៨៦ ៣៤៨

thecameliteschool@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Cambodia-Korea Plastic Enterprise

**ថ្ងៃផុតកំណត់:** ០២ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ជាងភ្លើង (ចំនួន ០១នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានសញ្ញាប័ត្រផ្នែកបច្ចេកទេសភ្លើង ឬ សញ្ញាប័ត្រប្រហាក់ប្រហែល
- មានបទពិសោធន៍ខាងប្រព័ន្ធភ្លើងគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនកាន់តែប្រសើរ
- អាចនិយាយភាសាអង់គ្លេសនិងសរសេរកាន់តែប្រសើរ
- ស្លូតបូត អត់ធ្មត់ ស្មោះត្រង់ និង ឧស្សាហ៍ព្យាយាមធ្វើការងារ
- មានទទួលខុសត្រូវលើការងារ និងរៀនយកអ្វីដែលថ្មី

**សូមទំនាក់ទំនងតាមរយៈ**

០៧៧ ៦១៦ ៥៩២

Leang_vanndan@yahoo.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## RMA Cambodia Co., Ltd

**ថ្ងៃផុតកំណត់:** ០១ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើឡាន (ចំនួន ៣០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ភេទប្រុស អាយុពី20-50ឆ្នាំ
- ត្រូវមានបទពិសោធន៍យ៉ាងតិច ២ឆ្នាំ និងប្រវត្តិល្អក្នុងការបើកបរ
- ត្រូវមានសញ្ញាប័ត្របឋមភូមិឡើង
- ត្រូវមានប័ណ្ណបើកបរ និងមានសុពលភាពប្រើប្រាស់
- ត្រូវមានចំណេះដឹង និងអនុវត្តន៍បានយ៉ាងល្អទាក់ទងនឹងច្បាប់ចរាចរណ៍
- អាចនិយាយ និងស្តាប់ភាសាអង់គ្លេសបានខ្លះៗ
- ត្រូវមានសុខភាពល្អ

**សូមទំនាក់ទំនងតាមរយៈ**

ផ្ទះលេខ២៧ ផ្លូវ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ

០២៣ ៨៨៣ ៤៨៨

Recruitment.kh@rmagroup.net

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## Mondulkiri Coffee Company

**ថ្ងៃផុតកំណត់:** ០៥ មិថុនា ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. Service

២. Waiter

**លក្ខខណ្ឌជ្រើសរើស:**

- មានភាពស្រស់ស្រាយ នឹង រស់រាយរាក់ទាក់
- ជាសិស្សដែលបានបញ្ចប់បាក់ឌុប រឺ ធ្លាក់បាក់ឌុប និង និស្សិតសិក្សានៅឆ្នាំទី ១ ឬ ទី ២ ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យធ្វើការ
- មានបទពិសោធន៍ ឬ គ្មានបទពិសោធន៍
- មានឆន្ទៈក្នុងការរៀនពីការងារ ឧស្សាហ៍ព្យាយាម និងឱ្យតម្លៃការងារនៅក្នុងភោជនីយដ្ឋាន
- ធ្លាប់យល់ដឹងនិងរៀនពីការងារនេះខ្លះៗកាន់តែប្រសើរ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២១ABE0 ផ្លូវ៦១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០៩៩ ៦០៦ ០៣៧/០៧០ ៧៩៤ ៩៣៩

job@mondulkiri-coffee.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## 103 New Production Co.,Ltd

**ថ្ងៃផុតកំណត់:** ២៨ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកលក់ (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- បុគ្គលិកភេទប្រុស
- កំពុងសិក្សានៅសាកលវិទ្យាល័យ រឺចប់ថ្នាក់ទី ១២
- មានការតាំងចិត្តចំពោះការងារ
- មានភាពស្មោះត្រង់
- ចេះប្រើប្រាស់កុំព្យូទ័រ Ms. Office បាន
- ចេះអាន និងសរសេរភាសាអង់គ្លេសបាន
- ចេះទំនាក់ទំនងល្អជាមួយអតិថិជន (ចំពោះផ្នែកលក់)
- មានទំនាក់ទំនងល្អជាមួយក្រុមការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៨៦ ផ្លូវនរោត្តម រាជធានីភ្នំពេញ

☎ ០៧០ ៣២២ ១០៣/០២៣ ២១២ ០៩៦

sokun@103npt.com.kh

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## The Ocean School

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. គ្រូភាសាចិន និងអង់គ្លេស (ចំនួន ១០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ក្នុងការបង្រៀនយ៉ាងតិច១ឆ្នាំ
- មានភាពអត់ធ្មត់ក្នុងការងារ
- មានភាពរួសរាយរាក់ទាក់ ស្មោះត្រង់

**សូមទំនាក់ទំនងតាមរយៈ:**

អគារA.92, 93, 94 បុរីសន្តិភាព២ សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ

☎ ០១៦ ៧០០ ៧០១ / ០១៧ ៩៦៨ ៩៦៧

kimlenglong@yahoo.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## អគ្គារធនធានមនុស្សអាស៊ាន

**ថ្ងៃផុតកំណត់:** ១៣ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកដឹកជញ្ជូន

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ទាក់ទងមុខតំណែង
- មានបណ្ណបើបរ
- មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន
- មានទំនាក់ទំនងល្អជាមួយអតិថិជន

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១១៨A ផ្លូវ៣៧១ ជិតស្ថានីយ៍ទូរទស្សន៍ប៊ុស្តបាយ័ន មានជ័យប្រែកចូលផ្លូវជាប់ហាងគុយទាវពន្លឺស្មី

☎ ០៩៣ ៧០០ ៦១៥

✉ aseanhro@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## អគ្គារលើកកម្ពស់សេដ្ឋកិច្ចកសិករ

**ថ្ងៃផុតកំណត់:** ២០ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:**

**មុខតំណែង:**

១. មន្ត្រីឥណទាន

**លក្ខខណ្ឌជ្រើសរើស:**

- កំរិតវប្បធម៌ចាប់ពីមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប)ឡើងទៅ , អាចធ្វើការងារជាក្រុម ។
- មានទំនាក់ទំនងល្អ , មានគំនិតឆ្នៃប្រឌិត , គំនិតបង្កើតថ្មី , មានភាពស្មោះត្រង់ និងមានឆន្ទៈខ្ពស់ក្នុងការងារ ។
- មានម៉ូតូផ្ទាល់ខ្លួន , មានកាយសម្បទាគ្រប់គ្រាន់ និង យល់ព្រមបំរើការងារតាមការចាត់តាំងរបស់អ្នកគ្រប់គ្រង ។

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៤០៩ ផ្លូវ១១ (បូរីពិភពថ្មីចំការដូង) ភូមិសំបួរ សង្កាត់ដង្កោ រាជធានីភ្នំពេញ

☎ ០១២ ៨២ ៥១ ៥២

✉ mechmunna99@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Nuk Café

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. Cashier/Services (ចំនួន ១០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង
- អាចនិយាយភាសាអង់គ្លេសបាន
- ត្រូវមានភាពរហ័សរហួន ម្ចាស់ការ និងចេះទទួលខុសត្រូវលើការងាររបស់ខ្លួន
- ស្មោះត្រង់ រួសរាយរាក់ទាក់ ឧស្សាព្យាយាម
- កំរិតសិក្សាចាប់ពី វិទ្យាល័យឡើងទៅ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្លូវ១៥៤ ផ្ទះលេខ16E0 សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០៦៩ ២២៥ ២២៨

✉ wuelaine09@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## China Duty Free Group (Cambodia) Co., Ltd

**ថ្ងៃផុតកំណត់:** ២៩ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកបោសសម្អាត (ចំនួន ០៨នាក់)

២. សន្តិសុខ (ចំនួន ០៦នាក់)

៣. បុគ្គលិកផ្នែកលក់ (ចំនួន ១០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- បញ្ចប់ថ្នាក់បរិញ្ញាបត្រសម្រាប់មុខតំណែងផ្នែកលក់
- កំរិតវប្បធម៌ត្រឹមថ្នាក់ទី៩ឡើងទៅ
- និយាយ អាន សរសេរភាសាអង់គ្លេសបានមធ្យម
- ត្រូវយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ខ្លួនអោយបានច្បាស់លាស់
- មានភាពស្មោះត្រង់ និងអត់ធ្មត់
- មានទំនួលខុសត្រូវខ្ពស់ និងយកចិត្តទុកដាក់នឹងការងារ
- មានបទពិសោធន៍បោសសម្អាតរយៈពេល១ឆ្នាំឡើងទៅ
- បទពិសោធន៍ក្នុងការការពារសន្តិសុខនិងល្បាត
- រូបរាងរាងកាយល្អ រឹងមាំ និងស្វាហាប់
- មានបទពិសោធផ្នែកសន្តិសុខរយៈពេល១ឆ្នាំ ឡើងទៅ
- ត្រូវមានរូបសម្បត្តិសម្បូរម្យ
- និយាយ អាន សរសេរ ភាសាអង់គ្លេសបានមធ្យម
- ត្រូវយកចិត្តទុកដាក់ការងារ, មានភាពស្មោះត្រង់, ចេះធ្វើការងារជាក្រុម និងមានទំនាក់ទំនងល្អ

**សូមទំនាក់ទំនងតាមរយៈ:**

ការិយាល័យ អាគារលេខ៥៨ ផ្លូវ៣៣៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០២៣ ៦៧៨៩ ៨១១ / ០១៦ ៥២៨ ០៥២

☎ ០៨៦ ៧៨ ៧៩ ០១

Cdfg.cambodiahr@cdfg.com.cn

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## CDL-HR

**ថ្ងៃផុតកំណត់:** ០៦ មិថុនា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ (ចំនួន ០៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ស្មោះត្រង់និងសុភាពរាបសា
- យកចិត្តទុកដាក់ក្នុងម៉ោងធ្វើការ
- មានរូបសម្ុបត្តិសមរម្យ

**សូមទំនាក់ទំនងតាមរយៈ:**

ហាងនំ Tous Les Jours ផ្លូវមន្នីវង្ស អាគារលេខ២២៩៨ ជាន់ទី១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០២៣ ៩៦៤ ៧៦៤

cdi@cdi-consultant.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
Ministry of Labour and Vocational Training
វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
National Polytechnic Institute of Cambodia

អាហារូបករណ៍ពិសេស
និស្សិតនារី : ទទួលបានការបញ្ចុះតម្លៃ ៣០%
និស្សិតលេខ ១ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ១០០%
និស្សិតលេខ ២ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ៣០%
និទ្ទេស A : ទទួលបានអាហារូបករណ៍ ១០០%
និទ្ទេស B : ទទួលបានអាហារូបករណ៍ ៥០%
និទ្ទេស C : ទទួលបានអាហារូបករណ៍ ៣០%

មានបណ្តុះបណ្តាលលើជំនាញ
- វិស្វករអគ្គិសនី
- វិស្វករមេកានិក
- វិស្វករសំណង់ស៊ីវិល
- វិស្វករអេឡិចត្រូនិក
- ភាសាកូរ៉េ
- គ្រប់គ្រងបច្ចេកវិទ្យា
- វិទ្យាសាស្ត្រកុំព្យូទ័រ
- វិជ្ជាជីវៈគណនេយ្យ
- អក្សរសាស្ត្រអង់គ្លេស
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

និស្សិតនឹងទទួលបាន
- ការប្រើប្រាស់ប្រព័ន្ធ អ៊ិនធើណេត និង WiFi ដោយឥតគិតថ្លៃក្នុងបរិវេណរបស់វិទ្យាស្ថានសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ។
- មានអន្តេវាសិកដ្ឋានដ៏ធំទូលាយសម្រាប់និស្សិតមកពីតាមខេត្តក្រុងនានា ។
- សេវាកម្មរថយន្តដឹកជញ្ជូននិស្សិតដែលស្នាក់នៅក្នុងក្រុងភ្នំពេញ ។
- មានអ្នកជំនាញការជាតិ និងអន្តរជាតិ នៅគ្រប់មហាវិទ្យាល័យ ។
- សាស្ត្រាចារ្យខ្មែរមានសញ្ញាបត្រ អនុបណ្ឌិត,បណ្ឌិត និងបទពិសោធន៍យូរឆ្នាំ ។
- រាល់កម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារស្តង់ដាជាតិ និងអន្តរជាតិ ។
- បន្ទប់ទ្រឹស្តី និងអនុវត្តន៍មានឧបករណ៍សម្ភារៈប្រើប្រាស់តាមបច្ចេកវិទ្យាទំនើប ។

ម៉ោងសិក្សា
- ថ្ងៃចន្ទ ដល់ សុក្រ (០៨.០០-១២.០០ និង ១៣.០០-១៦.០០)
- ថ្នាក់បន្តវិស្វករ ឬបរិញ្ញាបត្របច្ចេកវិទ្យា
  ថ្ងៃសៅរ៍-អាទិត្យ ០៨.០០-១២.០០ និង ១៣.០០-១៧.០០
- ម.វិ វិទ្យាសាស្ត្រកុំព្យូទ័រ និងម.វិ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
  វេនព្រឹក ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ០៨.០០-១២.៣០
  វេនរសៀល ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ១៣.០០-១៧.៣០

អាស័យដ្ឋាន
- ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ(ក្បែរវត្តពូនភ្នំ)
- (023) 96 15 193 / 010 970 351 / 012 381 246 / 011 769 003
- www.npic.edu.kh ,Email: npicinfo@gmail.com


## វិទ្យាស្ថាន NPIC ប្រារព្ធពិធីខួប ១០ឆ្នាំ

វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានប្រារព្ធខួប ១០ឆ្នាំ នៃថ្ងៃបង្កើតវិទ្យាស្ថានកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ក្នុងនេះមានភ្ញៀវដែលជាដៃគូរសហប្រតិបត្តិការជាតិ អន្តរជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនបានចូលរួម ។ ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញបានចូលរួមជាអធិបតីភាពក្នុងកម្មវិធី និងបានសម្ពោធពិធីតាំងបង្ហាញនូវពិព័ណ៌ស្នាដៃនិស្សិតដែលមកពីគ្រប់មហាវិទ្យាល័យរបស់វិទ្យាស្ថានដែលនេះបង្ហាញពីចំណេះដឹងផ្នែកទ្រឹស្តីផ្សាភ្ជាប់កាអនុវត្តន៍ជាក់ស្តែងរបស់និស្សិតរទៅតាមកំរិត និងតាមជំនាញនិមួយៗរបស់និស្សិតវិទ្យាស្ថាន ។

គួររំលឹកផងដែរថា វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានអប់រំរបស់រដ្ឋដែលធំជាងគេនៅក្នុងប្រទេសកម្ពុជាដែលបានសាងសង់ឡើងក្រោមជំនួយកម្ចីសហប្រតិបត្តិការរវាងកម្ពុជា និងកូរ៉េខាងត្បូងហើយបានដាក់សម្ពោធឲ្យប្រើប្រាស់តាំងពីឆ្នាំ២០០៥ ។




## ទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាឆ្នាំ ២០១៥

សិស្សានុសិ្សសថ្នាក់ទី១២ របស់វិទ្យាល័យចំនួន ១៣ ដែលឋិតនៅក្នុង និងជុំវិញរាជធានីភ្នំពេញត្រូវបានអនុញ្ញាត្តិឲ្យមកធ្វើទស្សនកិច្ចសិក្សាក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាចាប់ពីខែមិថុនា-កក្កដា ឆ្នាំ ២០១៥ ។ គោលបំណងសំខាន់ក្នុងដំណើរទស្សនកិច្ចសិក្សានេះគឺ វិទ្យាស្ថានចង់បង្ហាញ និងណែនាំប្អូនៗសិស្សានុសិ្សសឲ្យយល់ដឹងពីសារៈសំខាន់ក្នុងការសិក្សាមុខជំនាញបច្ចេកទេសដែលជាជំនាញដែលកំពុងមានតម្រូវការខ្ពស់ឆ្លើយតបទៅតាមតម្រូវការចំបាច់លើទីផ្សារការងារក្នុងពេលបច្ចុប្បន្ន និងដើម្បីចូលរួមចំនែកអភិវឌ្ឍន៍សង្គមកម្ពុជាតាមរយៈការសិក្សាជំនាញបច្ចេកទេស ។




## បទបង្ហាញក្រុមហ៊ុន SOMA Group អំពីយន្តហោះ Drone ដល់និស្សិតអេឡិចត្រូនិកនៃវិទ្យាស្ថាន NPIC

បន្ទាប់ពីមានជំនួបពីភាគីរវាងតំណាងរបស់ក្រុមហ៊ុន SOMA GROUP ជាមួយតំណាងរបស់វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាកាលពីថ្ងៃទី០៥ ខែមិថុនាឆ្នាំ២០១៥ រួចមកក្រុមហ៊ុន SOMA GROUP បានរៀបចំសិក្ខា-សាលា( Workshop ) មួយដែលបានប្រព្រឹត្តិទៅ ៦ថ្ងៃក្រោយជំនួបពិភាក្សារវាងដៃគូសហប្រតិបត្តិការទាំងពីខាងលើ ។ គោលបំណងសំខាន់របស់សិក្ខាសាលានេះគឺផ្តោតលើបច្ចេកវិទ្យាយន្តហោះប្រភេទ Drone និងផ្តល់ឳកាសការងារជា Drone Pilot នៅក្នុងក្រុមហ៊ុនឲ្យដល់និស្សិតផ្នែកអេឡិចត្រូនិកនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ។





សូមមេត្តារង់ចាំទស្សនា
www.nea.gov.kh
ទីភ្នាក់ងារជាតិមុខរបរ និងការងារ
នាទី
ទីផ្សារការងារ និង មុខរបរ
នៅលើកញ្ចក់ទូរទស្សន៍:
អង្គារ 22h
ពុធ 17h
សុក្រ 10h:45mn
សុក្រ 10h
សៅរ៍ 11h
សៅរ៍ 11h
សៅរ៍ 12h
សៅរ៍ 14h
សៅរ៍/អាទិត្យ 13h
អាទិត្យ 10h /17h
TV3
SEATV
CNC
5
APSARA
PPCTV
CCTV
ឬលើគេហទំព័រ
www.nea.gov.kh
NATIONAL EMPLOYMENT AGENCY

## ដៃគូសហការសំខាន់ៗ

ស្ទូវិការ

# ការងារ ឬ បុគ្គលិក

សេវាសម្រាប់

## អ្នកស្វែងរកការងារ

- ការចុះឈ្មោះស្វែងរកការងារធ្វើ និងផ្សព្វផ្សាយប្រវត្តិរូបសង្ខេបដោយងាយស្រួល និងទូលំទូលាយ
- ព័ត៌មានជ្រើសរើសបុគ្គលិក និងការអប់រំបណ្តុះបណ្តាលគ្រប់ប្រភេទ
- ការជួយស្វែងរកការងារធ្វើគ្រប់ប្រភេទ និងទូលំទូលាយជាងគេបំផុត
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក
- ការណែនាំអំពីឱកាសការងារ និងការវាយតម្លៃអំពីលទ្ធភាពទទួលបានការងារ
- ការណែនាំអំពីការត្រៀមលក្ខណៈស្វែងរកការងារធ្វើ ឱកាសការងារ និងការអភិវឌ្ឍអាជីព
- ព័ត៌មានទីផ្សារការងារទូទៅ



សេវាសម្រាប់

## និយោជក

- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកដោយងាយស្រួល និងបានទូលំទូលាយជាងគេបំផុត
- ការផ្តល់ធនាគារទិន្នន័យអំពីអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទនិងច្រើនជាងគេបំផុត
- ការផ្តល់ទីតាំងការិយាល័យសម្រាប់ជ្រើសរើសបុគ្គលិក
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទដោយងាយស្រួល
- ការចុះដល់ទីកន្លែងរបស់និយោជកផ្ទាល់ដើម្បីប្រមូលព័ត៌មានជ្រើសរើសបុគ្គលិក
- ការណែនាំអំពីការជ្រើសរើសបុគ្គលិក
- ព័ត៌មានទីផ្សារការងារទូទៅ




លោកអ្នកអាចទាញយកកម្មវិធី NEA JOB SEARCH ពី Google play

NEA JOB SEARCH | ANDROID APP ON Google play

www.nea.gov.kh | National Employment Agency

### ម.ភ រាជធានីភ្នំពេញ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
023 633 6002 ឬ 077 232 378
ឬ016 786 655
jc_pp@nea.gov.kh

### ម.ភ ខេត្តបាត់ដំបង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
បាត់ដំបង ផ្លូវលេខ២០១ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
053 733 111 ឬ 016 926 655
jc_battambang@nea.gov.kh

### ម.ភ ខេត្តកំពត

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
កំពត ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត
033 210 277 ឬ 016 506 655
jc_kampot@nea.gov.kh

### ម.ភ ខេត្តកំពង់ចាម

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ចាម ផ្លូវលេខ៧ចាស់ ភូមិទី៧
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
042 210 277 ឬ 016 656 655
jc_kampongcham@nea.gov.kh

### ម.ភ ខេត្តសៀមរាប

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
សៀមរាប សង្កាត់ស្លក្រាម
ក្រុងសៀមរាប
063 210 277ឬ 016 536 655
jc_siemreap@nea.gov.kh

### ម.ភ ខេត្តស្វាយរៀង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
ស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង
044 715 277 ឬ 016 646 655
jc_svayrieng@nea.gov.kh

### ម.ភ ខេត្តកំពង់ធំ

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ធំ ភូមិអាចារ្យលាក់ សង្កាត់
អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
062 210 277 / 016 836 655
jc_kampongthom@nea.gov.kh

### ម.ភ ខេត្តព្រៃវែង

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តព្រៃវែង ភូមិ១សង្កាត់កំពង់លាវ
ក្រុងព្រៃវែង ខេត្តព្រៃវែង
081 786 655 / 043 210 277
jc_preyveng@nea.gov.kh

### ម.ភ ខេត្តតាកែវ

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
តាកែវ ក្នុងភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ
ខេត្តតាកែវ
032 210 277 ឬ 016 676 655
jc_takeo@nea.gov.kh

